**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលខេត្តកំពត**
លេខ:..៤៨....... ស.ស.រ

# សេចក្តីសម្រេច
## ស្តីពី
## ការទទួលស្គាល់ ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សាខេត្តកំពត

## ប្រធានក្រុមប្រឹក្សាខេត្តកំពត

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/ រកត/ ០៥១៤/ ៦៤៤ ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០១៤ របស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ **នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ត្រាស់បង្គាប់ទទួលស្គាល់សមាសភាពក្រុមប្រឹក្សាខេត្តកំពត ក្នុងអាណត្តិទី ២ ។
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក ។
- យោងប្រកាសលេខ ៤២៧៥ ប្រក ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។
- យោងលិខិតលេខ ១៤៧ សជណ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។
- យោងតាមលទ្ធផលនៃកិច្ចប្រជុំវិសាមញ្ញលើកទី១ អាណត្តិទី ២ របស់ក្រុមប្រឹក្សាខេត្ត នាថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០១៤ ។

# សម្រេច

**ប្រការ១**.-

ត្រូវបានទទួលស្គាល់ ប្រធាន អនុប្រធាន និងសមាជិក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សាខេត្តកំពត ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | | |
|---|---|---|---|---|
| ១- | លោកជំទាវ | **ភង សៅរ៍ឆន** | សមាជិកក្រុមប្រឹក្សាខេត្ត | ប្រធាន |
| ២- | លោកជំទាវ | **សំ ចរិយា** | សមាជិកក្រុមប្រឹក្សាខេត្ត | អនុប្រធាន |
| ៣- | លោកជំទាវ | **យូ សុគន្ធ** | អភិបាលរងខេត្ត | អនុប្រធាន |
| ៤- | លោកស្រី | **ច្រាំ សុភាព** | ប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត | អនុប្រធាន |
| ៥- | លោកស្រី | **ទិត សេដ្ឋា** | ប្រធានមន្ទីរកិច្ចការនារីខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៦- | លោកស្រី | **មុយ វិរ័ត្ន** | នាយករងរដ្ឋបាលសាលាខេត្ត | សមាជិក |
| ៧- | លោក | **ជិន វណ្ណថា** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | សមាជិក |
| ៨- | លោក | **ស សារឿន** | អនុប្រធានមន្ទីរផែនការខេត្ត | សមាជិក |
| ៩- | លោក | **គង់ អៀងរី** | អនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត | សមាជិក |
| ១០- | លោក | **កៅ រិទ្ធិ** | អនុប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្ត | សមាជិក |
| ១១- | លោកស្រី | **ឡុង សាវ៉ន** | អនុប្រធានមន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត | សមាជិក |
| ១២- | លោក | **ចាន់ រិទ្ធ** | អនុប្រធានមន្ទីរកសិកម្មខេត្ត | សមាជិក |
| ១៣- | លោកស្រី | **សេង សេរីរដ្ឋា** | ស្នងការរងនគរបាលខេត្ត | សមាជិក |
| ១៤- | លោក | **ទិត វឌ្ឍនា** | នាយកទីចាត់ការអន្តរវិស័យសាលាខេត្ត | សមាជិក |
| ១៥- | លោកស្រី | **យ៉េម សំអើន** | អនុប្រធានសមាគមក្រុមប្រឹក្សាឃុំ-សង្កាត់ | សមាជិក |
| ១៦- | លោក | **អ៊ែង ប្រុស** | អនុប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ១៧- | លោកស្រី | **សេង សុខុម** | អនុប្រធានមន្ទីរព័ត៌មានខេត្ត | សមាជិក |
| ១៨- | លោក | **គល់ សុខា** | អនុប្រធានមន្ទីររ៉ែ និងថាមពលខេត្ត | សមាជិក |
| ១៩- | លោក | **ពេជ រដ្ឋា** | អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត | សមាជិក |
| ២០- | លោក | **ឃី នាង** | អនុប្រធានមន្ទីរធនធានទឹក និងឧតុនិយមខេត្ត | សមាជិក |
| ២១- | លោកស្រី | **អ៊ុក សោភ័ណ្ឌ** | អនុប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត | សមាជិក |
| ២២- | លោក | **ជុំ ឯម** | អនុប្រធានមន្ទីរធម្មការ និងសាសនាខេត្ត | សមាជិក |
| ២៣- | លោកស្រី | **ប៉ុក ណៃត** | អនុប្រធានមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា-ព្រឹទ្ធសភា និងអធិការកិច្ចខេត្ត | សមាជិក |
| ២៤- | លោកស្រី | **ប៊ុន ណារី** | អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈខេត្ត | សមាជិក |
| ២៥- | លោក | **ឡូ វណ្ណារ៉ា** | អនុប្រធានមន្ទីរពាណិជ្ជកម្មខេត្ត | សមាជិក |
| ២៦- | លោកស្រី | **អ៊ុន សារី** | អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត | សមាជិក |
| ២៧- | លោក | **ឃឹម វណ្ណារ៉ា** | អនុប្រធានមន្ទីរទេសចរណ៍ខេត្ត | សមាជិក |
| ២៨- | លោក | **ឡុង ស្រេង** | អនុប្រធានមន្ទីរបរិស្ថានខេត្ត | សមាជិក |
| ២៩- | លោក | **ព្រាប សារ៉ុត** | អនុប្រធានមន្ទីរសុខាភិបាលខេត្ត | សមាជិក |
| ៣០- | លោក | **តែ ជិនណារិទ្ធ** | អនុប្រធានមន្ទីរឧស្សាហកម្ម និងសិប្បកម្មខេត្ត | សមាជិក |
| ៣១- | លោក | **សុខ ឆេង** | នាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពត | សមាជិក |

**ប្រការ២.-**

តួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សាខេត្ត ត្រូវអនុវត្តឱ្យបានស្របទៅតាមប្រកាសលេខ ៤២៧៥ ប្រក និងលិខិតលេខ ១៤៧ សជណ ដូចបានយោងខាងលើ ។

**ប្រការ៣.-**

រាល់លិខិតបទដ្ឋានទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៤.-**

គណៈអភិបាលខេត្ត ប្រធានមន្ទីរ-អង្គភាពជុំវិញខេត្ត ទីចាត់ការចំណុះរចនាសម្ព័ន្ធសាលាខេត្ត និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវអនុវត្តសេចក្ដីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។/.

កំពត ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ២០១៤

**ប្រធានក្រុមប្រឹក្សាខេត្ត**

**អ៊ុច ម៉េងហួរ**

***ចម្លងជូន***
- ក្រសួងមហាផ្ទៃ
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- លេខាធិការដ្ឋាន គ.ជ.អ.ប
- ដូចប្រការ៤
- ឯកសារ , កាលប្បវត្តិ